# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអាទិត្យទី៣នៃរដូវរង់ចាំនៅព្រះសហគមន៍សន្តយ៉ូសែប
# ព្រែធំ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩
## រៀបចំខ្លួននៅក្នុងរដូវរង់ចាំ

**អត្ថបទទី១៖ អេសាយ ៣៥,១-៦ក**

ចូរកម្លាចិត្តអ្នកដែលភ័យតក់ស្លុតថា ចូរមានចិត្តក្លាហានឡើង កុំភ័យខ្លាចអ្វីឡើយ!។ អស ៣៥,៤

**អត្ថបទទី២៖ យ៉ាកុប ៥,៧-១០**

បងប្អូនអើយ ចូរយកតម្រាប់តាមពួកព្យាការីដែលបានរងទុក្ខលំបាក និងមានចិត្តអត់ធ្មត់ ហើយថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះអម្ចាស់។ យក ៥,១០

**ដំណឹងល្អ៖ ម៉ាថាយ ១១,២-១១**

ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បណ្តាមនុស្សដែលកើតមកក្នុងលោកនេះខ គ្មាននរណាមានឋានៈធំជាងលោកយ៉ូហានបាទីស្តឡើយ។ ប៉ុន្តែ អ្នកណាតូចជាងគេនៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ អ្នកនោះប្រសើរលើសលោកយ៉ូហានទៅទៀត។ មថ ១១,១១

បងប្អូនជាទីស្រឡាញ់!

នៅក្នុងរដូវរង់ចាំ ជាពេលវេលាដើម្បីឲ្យយើងបង្ហាញអំណរសប្បាយដែលយើងមាននៅក្នុងខ្លួនរបស់យើង អត្ថបទនីមួយៗដែលយើងបានស្តាប់ថ្ងៃនេះបានណែនាំឲ្យយើងថែរក្សាអំណរសប្បាយហ្នឹង។ ខ្ញុំមានពីរចំណុចដើម្បីឲ្យយើងធ្វើដំណើរនៅក្នុងរដូវរង់ចាំ និងនៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទគឺ៖

**ចំណុចទីមួយ ឲ្យយើងមានចិត្តអត់ធ្មត់** នៅក្នុងអត្ថបទទីពីរ "**មើលចុះ! អ្នកភ្ជួររាស់ទន្ទឹងរង់ចាំភោគផលដ៏ថ្លៃវិសេសដែលដីផ្តល់ឲ្យ ដោយចិត្តអត់ធ្មត់ រហូតដល់បានផលនៅដើមរដូវ និងចុងរដូវ**"។ ការអត់ធ្មត់ វាផ្ទុយនឹងជីវិតរបស់យើងបច្ចុប្បន្ននេះដែលយើងចង់បានភ្លាមៗ នៅពេលកូនៗយំចង់បានទូរស័ព្ទលេងឪពុកម្តាយឲ្យភ្លាម ប៉ុន្តែពេលយើងចាស់ហើយយើងមិនចង់ស្លាប់ភ្លាមទេ។ សង្គមបច្ចុប្បន្ន នៅក្នុងរបៀបផ្សព្វផ្សាយណែនាំឲ្យយើងភ្លេចពេលវេលាទន្ទឹងរង់ចាំ ព្រះសហគមន៍បានឲ្យយើងបួនសប្តាហ៍ ដើម្បីរៀបចំចិត្តគំនិតក្នុងការទទួលស្វាគមន៍ព្រះយេស៊ូ ឲ្យយើងមានចិត្តអត់ធ្មត់។ នៅពេលយើងមានចិត្តអត់ធ្មត់ ណែនាំឲ្យយើងមានផ្លែយ៉ាងច្រើនដូចម្ចាស់ចំការ ប្រសិនបើគាត់ដាំភ្លាមហើយចង់បានផ្លែភ្លាមដោយប្រើគីមី ធ្វើឲ្យគាត់បង្ខូចដំណាំគាត់អស់ហើយ។ ផ្ទុយទៅវិញ ប្រសិនបើគាត់ធ្វើតាមធម្មជាតិបន្តិចម្តងៗគាត់ទទួលផលយ៉ាងច្រើននឹងមានរយៈពេលយូរ។ ជីវិតរបស់យើងក៏ដូចគ្នា នៅពេលយើងយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យកចិត្តទុកដាក់អធិដ្ឋាន យកចិត្តទុកដាក់ស្រឡាញ់ព្រះជាម្ចាស់ពីមួយថ្ងៃទៅ

មួយថ្ងៃ ជីវិតរបស់យើងរីកចម្រើននៅក្នុងភាពដ៏វិសុទ្ធយ៉ាងជ្រៅ។ ហេតុនេះហើយ នៅក្នុងពេលវេលារង់ចាំព្រះយេស៊ូដែលកំពុងយាងមកឲ្យយើងគិត **តើយើងថែរក្សាជំនឿ សេចក្តីស្រឡាញ់ ដូចម្តេចដើម្បីមានសមត្ថភាពទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងជីវិតខ្ញុំ និងចែករំលែកជាមួយបងប្អូនឯទៀតៗដែលប្រញាប់ៗរហូត?** នៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ ឲ្យយើងយកពេលដើម្បីអធិដ្ឋាន ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឲ្យយើងទៅជាអ្នកដ៏វិសុទ្ធនៅថ្ងៃអនាគត តែយើងត្រូវការពេលវេលាដែលទាមទារឲ្យយើងអត់ធ្មត់។ ការសិក្សា ក៏ត្រូវការការតស៊ូ ចិត្តអត់ធ្មត់ ដើម្បីឲ្យយើងអានបាននិងមានអនាគតល្អ ដូច្នេះឪពុកម្តាយត្រូវតែតស៊ូអត់ធ្មត់ក្នុងការជម្រុញការសិក្សារបស់កូន។

**ចំណុចទីពីរ ឲ្យយើងថែរក្សាអំណរសប្បាយ** មិនមែនជាអំណរសប្បាយតាមលោកិយ តែជាអំណរសប្បាយដែលមកពីព្រះជាម្ចាស់ផ្ទាល់។ អំណរសប្បាយនេះ ជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងយាងមក គឺមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់បានស្អាតបរិសុទ្ធ មនុស្សថ្លង់ស្តាប់ឮ និងមនុស្សស្លាប់បានរស់ឡើងវិញ នេះជាអំណរសប្បាយដែលមកពីព្រះជាម្ចាស់។ អំណរសប្បាយដែលណែនាំឲ្យយើងមានជីវិតថ្មី ពេលខ្លះយើងខ្វាក់ដែរ យើងថ្លង់ដែរ យើងឈឺដែរ និងណែនាំឲ្យយើងជាគ្រីស្តបរិស័ទចែលរំលែកដល់អ្នកដទៃដែលគ្មានទីពឹង។ យើងមានអាគារមួយនៅទួលក្រសាំងដែលក្រុមប្រឹង្សស៊ីស្ទ័រនឹងជូនមកព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខ្ញុំសង្ឃឹមថាយើងអាចធ្វើជាមជ្ឈមណ្ឌលជនពិការ និងកម្មវិធីមេត្តាករុណាផ្សេងៗ។ ព្រះសហគមន៍យើង ត្រូវការគិតពិចារណា **តើយើងធ្វើអ្វីខ្លះដើម្បីឲ្យមនុស្សខ្វិនដើរបាន មនុស្សខ្វាក់មើលឃើញ?** កុំឲ្យយើងធ្វើកម្មវិធីសង្គហៈសម្រាប់តែគ្នាយើង ឲ្យយើងបង្កើតកម្មវិធីដើម្បីបង្ហាញថានេះជាព្រះសហគមន៍កាតូលិក ដែលបានជួយបងប្អូនឯទៀតៗដែលមិនមែនជាគ្រីស្តបរិស័ទ។

ដោយនាមព្រះសហគមន៍កាតូលិក **តើយើងមានស្នាដៃអ្វីខ្លះដើម្បីសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ?** ដូចក្នុងអត្ថបទដែលយើងបានស្តាប់ថ្ងៃនេះមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់បានស្អាតបរិសុទ្ធ មនុស្សថ្លង់ស្តាប់ឮ និងមនុស្សស្លាប់បានរស់ឡើងវិញ។ ខ្ញុំសង្ឃឹមថា នៅទួលក្រសាំងដោយនាមព្រះសហគមន៍នៅក្នុងមណ្ឌលសកម្មភាពទន្លេបាសាក់ យើងមានកម្មវិធីមួយស្ថិតស្ថេរដើម្បីជួយបងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទ ជាពិសេសអ្នកតូចតាចនិងអ្នកដែលសង្គមមិនអើពើ។ ខ្ញុំសង្ឃឹមថានៅតាមមណ្ឌលសកម្មភាពនីមួយៗក៏ដូចគ្នាដែរ ដើម្បីណែនាំឲ្យព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគភ្នំពេញអនុវត្តព្រះបន្ទូលរបស់ព្រះជាម្ចាស់និងធ្វើជាសាក្សីនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលកំពុងយាង

មកតាមរយៈព្រះយេស៊ូ និងព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលព្រះយេស៊ូបានប្រកាសអស់រយៈពេលបីឆ្នាំនៅស្រុកកាលីឡេ។

យើងអធិដ្ឋាន ដើម្បីឲ្យយើងមានចិត្តអត់ធ្មត់ និងដើម្បីឲ្យយើងថែរក្សាអំណរសប្បាយជានិច្ច។ អាម៉ែន៕